ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Dec-2012, 14:13
CMS/CFO: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក(២១)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (21)

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រ៊ឹម ជាប្រធាន |
| | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម Agnieszka KLONOWIECKA-MILART |
| | ចៅក្រម ម៉ុង មុនីចរិយា |
| | ចៅក្រម Florence Ndepele Mwachande MUMBA |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១២ |
| ភាសា៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# សេចក្តីសម្រេចលើសំណើសុំពន្យារពេលក្នុងការដាក់បណ្តឹងសាទុក្ខភ្លាមៗ

---

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា

**មេធាវីជនជាប់ចោទ**

សុន អរុណ

Michiel PESTMAN
Victor KOPPE

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

១. **អង្គជំនុំជម្រះតុលាការកំពូល** ("អ.ជ.ត.ក") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") សម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ បានទទួលសំណើមួយ ដែលសហមេធាវីរបស់ នួន ជា ("មេធាវីការពារក្តី") បានដាក់កាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ ដែលបានស្នើសុំការពន្យារពេលរហូតដល់ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ ដើម្បីដាក់បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានដាក់កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ពាក់ព័ន្ធនឹងសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ ប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា[1]។ មេធាវីការពារក្តីក៏បានស្នើសុំការអនុញ្ញាតដើម្បីដាក់ជាភាសាអង់គ្លេស នូវបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចមួយទៀត របស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានដាក់កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ពាក់ព័ន្ធនឹងសំណើសុំវិធានការបន្ទាន់ ប្រឆាំងនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាលចូលកិច្ចការរដ្ឋបាលរបស់តុលាការ ដោយការបកប្រែជាភាសាខ្មែរនឹងមានឆាប់ៗតាមដែលអាចធ្វើទៅបាន[2]។ ក្នុងការគាំទ្រសំណើនេះ មេធាវីការពារក្តីបានអះអាងថា ការខ្វះភាពជាក់លាក់អំពីនីតិវិធី និងពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខភ្លាមៗ បានកើតឡើងកាលពីពេលថ្មីៗ[3]។ សហព្រះរាជអាជ្ញាពុំបានឆ្លើយតបទៅនឹងសំណើនេះទេ ។

២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដែលបានបញ្ជាក់អំពីពេលវេលាមិនធ្វើសវនាការសម្រាប់ឆ្នាំ ២០១២ ដែលរួមបញ្ចូលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ដល់ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១៣ ("ការសម្រាកមិនធ្វើសវនាការនាសិសិររដូវ") ដែលនៅក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះសាលាដំបូងនឹង

[1] សំណើសុំពន្យារពេលដើម្បីដាក់បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ដោយអនុលោមតាមវិធាន ៣៥, ឯកសារ E219/3/1/1.1, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ ("សំណើ"), កថាខណ្ឌ ១-៥, *ដែលយោងទៅលើ* សេចក្តីសម្រេចលើសំណើអនុលោមតាមវិធាន ៣៥ ដែលសុំឱ្យមានចំណាត់ការជាបន្ទាន់ចំពោះរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង (ឯកសារ E219), ឯកសារ E219/3, ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ និងដែលបានដាក់នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើចំណាត់ការបន្ទាន់")។

[2] សំណើ, កថាខណ្ឌ ៦, *ដែលយោងទៅលើ* សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារ E189/3 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ និងដែលបានដាក់នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើវិធានការជាបន្ទាន់")។

[3] សំណើ, កថាខណ្ឌ ១-៦។

មិនធ្វើសវនាការ ហើយការដាក់ឯកសារនឹងពុំត្រូវបានអនុញ្ញាត[4]។ អនុស្សរណៈឆ្នាំ ២០១២ បានបញ្ជាក់ថា "នៅក្នុងអំឡុងពេលនៃថ្ងៃផ្អាកមិនធ្វើសវនាការដូចបញ្ជាក់ខាងលើ [...] ផ្នែកគ្រប់គ្រងតុលាការនឹងមិនទទួលឯកសារណាមួយសម្រាប់ដាក់ចូលក្នុងសំណុំរឿង ០០២ ឡើយ" ហើយ "ក្នុងករណីដែលពេលវេលាកំណត់ចូលក្នុងថ្ងៃណាមួយក្នុងអំឡុងថ្ងៃសំរាកខាងលើ កាលបរិច្ឆេទសម្រាប់ការដាក់ឯកសារគឺគិតនៅថ្ងៃចូលធ្វើការដំបូងក្រោយថ្ងៃផ្អាកសវនាការ"[5]។

៣. កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានទទួលការសាកសួរមួយអំពីនីតិវិធីនៃការដាក់បណ្តឹងសាទុក្ខភ្លាមៗ ដែលពេលវេលាកំណត់ស្ថិតនៅក្នុងអំឡុងពេលនៃការសម្រាកមិនធ្វើសវនាការនាសិសិររដូវ[6]។ អង្គជំនុំជម្រះតុលាការកំពូលបានឆ្លើយតបថា ពេលវេលាកំណត់នៃការដាក់ឯកសារទាំងអស់ និងនីតិវិធីដូចមានបញ្ជាក់ក្នុងវិធានផ្ទៃក្នុង[7] និងសេចក្តីណែនាំអនុវត្ត[8] គួរត្រូវបានអនុវត្តដូចសព្វមួយដង[9]។ នៅថ្ងៃបន្ទាប់ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដែលបានបញ្ជាក់អំពីពេលវេលាមិនធ្វើសវនាការសម្រាប់ឆ្នាំ ២០១៣ ដែលបានគូសបញ្ជាក់អំពីនីតិវិធីនៃការដាក់ឯកសារដែលស្រដៀងនេះ និងពេលវេលាកំណត់ដូចនៅក្នុងអនុស្សរណៈឆ្នាំ ២០១២ ដែរ ប៉ុន្តែលើកនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ការអនុវត្តបែបនេះមិនប៉ះពាល់ដល់ការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះផ្សេងទៀតទេ ដោយរួមបញ្ចូលទាំងការដាក់បណ្តឹងសាទុក្ខភ្លាមៗផងដែរ"[10]។

៤. អនុលោមតាមវិធាន ៣៩(៣) និងវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឲ្យមានចំណាត់ការបន្ទាន់ និងសេចក្តីសម្រេចលើ

---

[4] អនុស្សរណៈពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ពេលវេលាដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១២" ឯកសារ E165, ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ("អនុស្សរណៈឆ្នាំ ២០១២")។

[5] អនុស្សរណៈឆ្នាំ ២០១២, កថាខណ្ឌ ២។

[6] សារអេឡិចត្រូនិកពី Tanya Rene PETTAY អ្នកពិគ្រោះយោបល់ផ្នែកច្បាប់របស់ អៀង សារី ដែលមានចំណងជើងថា "សំណួរពាក់ព័ន្ធនឹងពេលវេលាមិនធ្វើសវនាការនាសិសិររដូវ" ដែលបានផ្ញើនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២ នាវេលាម៉ោង ១២ និង ២១ នាទី។

[7] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក, វិសោធនកម្មលើកទី ៨, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។

[8] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, វិសោធនកម្មលើកទី ៨, ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្ត")។

[9] សារអេឡិចត្រូនិកពី Sheila PAYLAN, មន្ត្រីច្បាប់នៃអង្គជំនុំជម្រះតុលាការកំពូល, ដែលមានចំណងជើងថា "តប៖ សំណួរពាក់ព័ន្ធនឹងពេលវេលាមិនធ្វើសវនាការនាសិសិររដូវ" ដែលត្រូវបានផ្ញើនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២ នាវេលាម៉ោង ១៦ និង ១២ នាទី។

[10] អនុស្សរណៈពីចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "កាលបរិច្ឆេទដែលអង្គជំនុំជម្រះមិនធ្វើ សវនាការក្នុងឆ្នាំ ២០១៣" ឯកសារ E253, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ("អនុស្សរណៈឆ្នាំ ២០១៣"), កថាខណ្ឌ ២។

សំណើសុំឱ្យមានចំណាត់ការភ្លាមៗ ទាំងពីរនេះ គឺនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២[11]។ មេធាវីការពារក្ដីអះអាងថាផ្អែកតាមអនុស្សរណៈឆ្នាំ ២០១២ ខ្លួនបានសន្និដ្ឋានថា ពេលវេលាកំណត់ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ត្រូវបាន "លើក" ទៅថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ វិញ[12]។ ដោយចង្អុលទៅវិធាន ១០៦(២) នៃវិធានផ្ទៃក្នុងដែលចែងថា "បណ្ដឹងសាទុក្ខភ្លាមៗត្រូវដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង" មេធាវីការពារក្ដីបានអះអាងថា ការសន្និដ្ឋានរបស់ខ្លួនដែលថាបណ្ដឹងសាទុក្ខភ្លាមៗនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលបានរងការប៉ះពាល់ គឺជាការសន្និដ្ឋានសមហេតុផល[13]។ ហេតុដូច្នេះ សំណើរបស់មេធាវីការពារក្ដីត្រូវបានធ្វើឡើងដោយអនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្ត ដើម្បីជួសជុលសងនូវពេលវេលារបស់ពួកគាត់ក្នុងការដាក់បណ្ដឹងសាទុក្ខភ្លាមៗទាំងពីរ ដែលត្រូវបាន "កាត់បន្ថយយ៉ាងច្រើនដោយពុំមានការរំពឹងទុក"[14]។

៥. ជាវិធានទូទៅ ពេលវេលាកំណត់នៃការដាក់ឯកសារត្រូវបានពន្យារ លុះត្រាតែពេលវេលាទាំងនោះត្រូវនឹងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃឈប់សម្រាកជាសាធារណៈនៅកម្ពុជា ឬថ្ងៃឈប់សម្រាកផ្លូវការផ្សេងៗដែល អ.វ.ត.ក ឈប់សម្រាក ប៉ុណ្ណោះ[15]។ វិធាន ៣៩(១) នៃវិធានផ្ទៃក្នុងចែងអំពីលទ្ធភាពដែលពេលវេលាកំណត់ដែលត្រូវបានដាក់ *ក្នុងចំណោមចំណុចផ្សេងៗ* "តាមរយៈការសម្រេចរបស់ចៅក្រម" ប៉ុន្តែ "ក្នុងករណីសមស្រប" ប៉ុណ្ណោះ។ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងក៏ផ្ដល់សិទ្ធិអំណាចឱ្យចៅក្រម "ពន្យារពេលវេលាកំណត់ណាមួយដែលពួកគាត់បានដាក់" ឬ "ទទួលស្គាល់សុពលភាពនៃចំណាត់ការណាមួយដែលត្រូវបានអនុវត្ត បន្ទាប់ពីពេលផុតរលត់នៃពេលវេលាកំណត់ ដូចមានចែងក្នុងវិធានផ្ទៃក្នុងទាំងនេះអំពីលក្ខខណ្ឌទាំងនេះ ប្រសិនបើមាន នៅពេលពួកគាត់យល់ថាសមស្រប"[16]។ រយៈពេលណាមួយដែលអង្គជំនុំជម្រះសាលាដំបូងគូសបញ្ជាក់ថា ខ្លួននឹងពុំធ្វើសវនាការ ពុំចាត់ទុកជាថ្ងៃឈប់សម្រាកជាផ្លូវការឡើយ ហើយពុំមានអានុភាពលើភារកិច្ចតាមផ្លូវតុលាការ ដែលអង្គជំនុំជម្រះតុលាការកំពូលមានកាតព្វកិច្ចដើម្បីអនុវត្តឡើយ។

៦. ពុំមានអ្វីមួយនៅក្នុងវិធានផ្ទៃក្នុង ឬសេចក្ដីណែនាំអនុវត្ត ដែលផ្ដល់សិទ្ធិអំណាចទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីហាមឃាត់ផ្នែកគ្រប់គ្រងតុលាការ មិនឱ្យទទួលយកការដាក់ឯកសារនៅក្នុងអំឡុងពេល

---

[11] សេចក្ដីជូនដំណឹងជាមុនអំពីសេចក្ដីសម្រេចនាពេលបច្ចុប្បន្នរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើត្រូវបានផ្ដល់ទៅមេធាវីការពារក្ដី តាមរយៈសារអេឡិចត្រូនិកនៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២ នាវេលាម៉ោង ១៣ និង ៥៩ នាទី។

[12] សំណើ, កថាខណ្ឌ ១-៣។

[13] សំណើ, កថាខណ្ឌ ៣-៥។

[14] សំណើ, កថាខណ្ឌ ៥។

[15] *សូមមើល* វិធាន ៣៩(៣)នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* មាត្រា ២.៣ នៃសេចក្ដីណែនាំអនុវត្ត។

[16] *សូមមើលផងដែរ* មាត្រា ៨.១ នៃសេចក្ដីណែនាំអនុវត្ត។

វេលាដែលមិនធ្វើសវនាការឡើយ។ លើកលែងតែមានការណែនាំផ្សេងពីនេះដោយការិយាល័យរដ្ឋបាល អ.វ.ត.ក ជានិច្ចកាលត្រូវបានចាត់ទុកជាតុលាការបើកចំហ និងធ្វើប្រតិបត្តិការ រួមទាំងសម្រាប់គោលបំណងនៃការដាក់ឯកសារផងដែរ[17]។ ហេតុដូច្នេះ ថ្វីបើអង្គជំនុំជម្រះសាលាដំបូងអាចយល់ថាជាការសមស្របដើម្បីពន្យារពេលវេលាកំណត់នៃការដាក់ឯកសារក្នុងអំឡុងពេល ដែលខ្លួនមិនធ្វើសវនាការក៏ដោយ ក៏គ្មានហេតុផល ឬមូលដ្ឋានណាមួយដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូង ហាមឃាត់ភាគីមិនឲ្យដាក់ឯកសារ ដោយស្ម័គ្រចិត្ត ឬសំណើថ្មី ឬ ចម្លើយតប នៅមុនពេលវេលាកំណត់ដែលត្រូវបានពន្យារក្នុងអំឡុងពេលទាំងនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងអនុស្សរណៈឆ្នាំ ២០១២ បានធ្វើឱ្យមានការភាន់ច្រឡំអំពីនីតិវិធី និងពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងសាទុក្ខភ្លាមៗ ហើយការភាន់ច្រឡំនេះ គឺជាមូលហេតុដ៏ល្អមួយក្នុងការអនុញ្ញាតតាមសំណូមពរដែលមេធាវីការពារក្តីបានស្នើសុំ។

៧. តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះតុលាការកំពូល**អនុញ្ញាត**តាមសំណើសុំនេះទាំងមូល។

ភ្នំពេញថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

[17] ការិយាល័យរដ្ឋបាលបានចេញអនុស្សរណៈដែលបញ្ជាក់អំពីថ្ងៃឈប់សម្រាកផ្លូវការ ដែលអនុវត្តដោយ អ.វ.ត.ក។ គ្មានអ្វីមួយនៅក្នុងអនុស្សរណៈទាំងនេះ គាំទ្រសេចក្តីសន្និដ្ឋានណាមួយដែលថាផ្នែកគ្រប់គ្រងតុលាការ នឹងពុំទទួលការដាក់ឯកសារក្នុងអំឡុងកាលបរិច្ឆេទ មិនធ្វើសវនាការឡើយ។ *សូមមើល* សារាចរព័ត៌មានពី ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និង Knut RoSANDHAUG អនុប្រធានការិយាល័យរដ្ឋបាល ដែលមានចំណងជើងថា "ថ្ងៃឈប់សម្រាកជាផ្លូវការសម្រាប់ឆ្នាំ ២០១២" ឯកសារ E165.1, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១។ *សូមមើលផងដែរ* សារាចរព័ត៌មានពី ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និង Knut RoSANDHAUG អនុប្រធានការិយាល័យរដ្ឋបាល និងជាមន្ត្រីសម្របសម្រួលនៃភាគីអន្តរជាតិនៃសាលាក្តីខ្មែរក្រហម ដែលមានចំណងជើងថា "ថ្ងៃឈប់សម្រាកជាផ្លូវការសម្រាប់ឆ្នាំ ២០១៣" ឯកសារ E253.1, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២។